ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៤៧..សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូ ពិភាក្សាការងារជាមួយផ្នែកឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការចាត់តាំងសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល និងជាសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧០អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

- យោងសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១ និងសេចក្តីសំរេចលេខ ៤១ សសរ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាការងារ ជាមួយវិស័យឯកជន
- អនុលោមតាមតំរូវការចាំបាច់នៃការងារ

## សំរេច

ប្រការ ១ : បង្កើតក្រុមការងារតំណាងអោយភាគីរាជរដ្ឋាភិបាល សំរាប់វិស័យ ០៧ ក្នុងក្របខ័ណ្ឌវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន សំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន។ ក្រុមការងារទាំង ០៧ នេះ ខាងផ្នែករាជរដ្ឋាភិបាល មានសមាសភាពដូចខាងក្រោម :

**ក. ក្រុមការងារផ្នែកកសិកម្ម និងកសិ-ឧស្សាហកម្ម :**

| | | |
|---|---|---|
| ១- ឯកឧត្តម ចាន់ សារុន | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សហប្រធាន |
| ២- ឯកឧត្តម ជា ស៊ានហុង | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | អនុប្រធាន |
| ៣- ឯកឧត្តម ម៉ិន អ៊ីយ | រដ្ឋលេខាធិការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- ឯកឧត្តម អេង ហួត | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៥- ឯកឧត្តម គឹម ស៊ីថន | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- ឯកឧត្តម កែវ ខេមរា | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧- ឯកឧត្តម យ៉ិន គឹមស៊ាន | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- ឯកឧត្តម ស្រ៊ុន តារា | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- ឯកឧត្តម ភួយ សុខារិទ្ធ | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១០-ឯកឧត្តម នូ តៀង | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១១-ឯកឧត្តម សួន សិរិទ្ធី | អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |

**ខ. ក្រុមការងារផ្នែកទេសចរណ៍ :**

| | | |
|---|---|---|
| ១- ឯកឧត្តម ឡាយ ប្រហស្ស | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សហប្រធាន |
| ២- ឯកឧត្តម សុខ ចិន្តា | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣- ឯកឧត្តម សេង លឹមនៅ | រដ្ឋលេខាធិការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- ឯកឧត្តម ប្រាជ្ញ ស៊ុន | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៥- ឯកឧត្តម សួង ម៉េងគា | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម អ៊ុក សុជាតិ | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧- ឯកឧត្តម សុខ សុនី | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |

| | | |
|---|---|---|
| ៨- ឯកឧត្តម ស៊ឹម ស៊ុឡេង | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៩- ឯកឧត្តម កែវ សាផល | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ១០-ឯកឧត្តម នេព ហោន | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ១១ ឯកឧត្តម នេត សាវឿន | អគ្គស្នងការនគរបាលជាតិក្រសួងមហាផ្ទៃ | សមាជិក |

## គ. ក្រុមការងារផ្នែកកម្មន្តសាល និងសហគ្រាសធុនតូច-មធ្យម :

| | | |
|---|---|---|
| ១- ឯកឧត្តម ស៊ុយ សែម | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សហប្រធាន |
| ២- ឯកឧត្តម ម៉ៅ ធាយលាង | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- ឯកឧត្តម សុខ សាន | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៤- ឯកឧត្តម តឿង សុគ័ណ្ឌ | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥- ឯកឧត្តម អ៊ឹង គិរុន | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៦- ឯកឧត្តម ថោង ខុន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧- ឯកឧត្តម ង៉ី តាយី | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- ឯកឧត្តម ឆា ដុប | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៩- ឯកឧត្តម តូច ចាន់កុសល | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០-ឯកឧត្តម សយ សុខា | អគ្គលេខាធិការក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១-ឯកឧត្តម សួន សិទ្ធី | អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១២-ឯកឧត្តម អ៊ិត ណូឌី | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣-ឯកឧត្តម ស្រ៊ុន ទិព្វទណ្ណៈ | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |

## ឃ. ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច :

| | | |
|---|---|---|
| ១- ឯកឧត្តម គាត ឈន់ | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សហប្រធាន |
| ២- ឯកឧត្តម គង់ វិបុល | រដ្ឋលេខាធិការទី១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានទី១ |
| ៣- ឯកឧត្តម សុខ ចិន្តា | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៤- ឯកឧត្តម ជា សុផារ៉ា | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥- ឯកឧត្តម ហ៊ី សោភា | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៦- ឯកឧត្តម គីម ស៊ីថន | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- លោកជំទាវ ប្រាក់ ចន្ថា | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

| | | |
|---|---|---|
| ៨- ឯកឧត្តម នុត សារអាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩- ឯកឧត្តម ស្វាយ ស៊ីថា | អនុរដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០-ឯកឧត្តម អ៊ឹង ម៉ុណ្ណារ៉ា | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១១-ឯកឧត្តម មាស គឹមសុវ៉ារី | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២-ឯកឧត្តម សូ ម៉ារ៉ា | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |

ង. <u>ក្រុមការងារផ្នែកសេវារាប់បញ្ចូលនិងសេវាធនាគារ និងហិរញ្ញវត្ថុ</u> :

| | | |
|---|---|---|
| ១- ឯកឧត្តម ជា ចាន់តូ | អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា | សហប្រធាន |
| ២- ឯកឧត្តម ជា ម៉េងឈាង | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម សុខ ចិន្ដា | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤- ឯកឧត្តម ម៉ុម ស៊ីមុន | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៥- ឯកឧត្តម នៅ កាស៊ី | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៦- ឯកឧត្តម ឯក ទណ្ឌឌី | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៧- ឯកឧត្តម សៀង ឡាប្រេស្ស | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨- ឯកឧត្តម សុខ ផេង | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៩- ឯកឧត្តម ជា សែ | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១០-ឯកឧត្តម អ៊ុំ មាន | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១១-ឯកឧត្តម ម៉ៅ ថូរ៉ា | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១២-ឯកឧត្តម គីម សុភ័ណ្ឌ | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ១៣-លោក តឹក រ៉េតសំរេច | ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

ច. <u>ក្រុមការងារផ្នែកថាមពល និងហេដ្ឋារចនាសម្ព័ន្ធ</u> :

| | | |
|---|---|---|
| ១- ឯកឧត្តម ស៊ុន ចាន់ថុល | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | សហប្រធាន |
| ២- ឯកឧត្តម អ៊ិត ប្រាំង | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និថាមពល | អនុប្រធាន |
| ៣- ឯកឧត្តម គង់ ហ៊ិនធារិទ្ធ | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៤- ឯកឧត្តម តាន់ ទុដ្ឋា | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៥- ឯកឧត្តម លី អៀមឡាក់ | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម ឌុច ហេង | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |

| | | |
|---|---|---|
| ៧- ឯកឧត្តម ភើត សារ៉េត | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៨- ឯកឧត្តម ម្ជូឌ សៅខន | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៩- ឯកឧត្តម ជា ឆាយ | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១០-ឯកឧត្តម អេង សួស្ដី | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ១១-ឯកឧត្តម សួន សិទ្ធី | អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១២-ឯកឧត្តម ជា វ៉ាន់ដេត | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |

ឆ- <u>ក្រុមការងារផ្នែកផលិតកម្មកែច្នៃសំរាប់នាំចេញ និងកិច្ចសំរួលពាណិជ្ជកម្ម</u> :

| | | |
|---|---|---|
| ១- ឯកឧត្តម ចម ប្រសិទ្ធ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សហប្រធាន |
| ២- ឯកឧត្តម សួង ហេង | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- ឯកឧត្តម សុខ ចិន្ដា | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤- ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ឯកឧត្តម អូស្មាន់ ហាសាន | រដ្ឋលេខាធិការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | សមាជិក |
| ៦- ឯកឧត្តម ខ្លូត រ៉ាន់ឌី | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៧- ឯកឧត្តម ខៀង មុត | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- ឯកឧត្តម ម៉ែន ស៊ីម៉ន | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ៩- ឯកឧត្តម ទា ជាង | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០-ឯកឧត្តម អ៊ុក សុខុន | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១-ឯកឧត្តម ឆា សុផ្លា | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ១២-ឯកឧត្តម ហ៊ីង ថូរ៉ាក់ស៊ី | ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |

<u>ប្រការ ២</u> : វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនត្រូវប្រព្រឹត្តឡើងនៅរៀងរាល់ ០៦ ( ប្រាំមួយ ) ខែម្ដង។ ក្នុងចន្លោះពេលមុនវេទិកាពេញអង្គ ក្រុមការងារនីមួយៗ មានភារកិច្ចសំខាន់ៗដូចតទៅ :

- ធ្វើការងារប្រទាក់ក្រឡាគ្នាជាមួយនឹងគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន ដែលត្រូវបានបង្កើតឡើងដោយសេចក្ដីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៤ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤
- ពិភាក្សាផ្លាស់ប្ដូរយោបល់ជាមួយដៃគូឯកជន ដើម្បីលើកឡើងនូវវិធានការដោះស្រាយ រាល់បាតុភាពអសកម្ម ដែលកើតមានក្នុងក្របខ័ណ្ឌវិស័យរបស់ខ្លួន អោយបានទាន់ពេលវេលា និងលើកជាសំណូមពរដោះស្រាយជូនស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធក្នុងករណីចាំបាច់ ។

- ពិនិត្យពិចារណាជាមួយផ្នែកឯកជនជាដៃគូ ក្នុងការលើកឡើងនូវរាល់គំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រ សំរាប់គាំទ្រលើកទឹកចិត្តបណ្តាក្រុមហ៊ុនកំពុងមានសកម្មភាព ក៏ដូចជាសំរាប់ទាក់ទាញការវិនិយោគ និងធុរកិច្ចថ្មីៗបន្ថែមទៀត មកកម្ពុជា។
- ធ្វើរបាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាល ពីសកម្មភាពការងារ និងពីទិសដៅភារកិច្ចដែលត្រូវអនុវត្តជាបន្ត ដើម្បីមានជាមូលដ្ឋានសំរាប់ប្រមុខរាជរដ្ឋាភិបាលផ្តល់ជាអនុសាសន៍ នៅរៀងរាល់វេទិការាជរដ្ឋាភិបាល-វិស័យឯកជន។
- ទទួលដោះស្រាយរាល់ការចាំបាច់ផ្សេងៗទៀត ក្នុងក្របខ័ណ្ឌវិស័យរបស់ខ្លួន តាមការប្រគល់ភារកិច្ចរបស់រាជរដ្ឋាភិបាល។

ប្រការ ៣ : ភារកិច្ចរបស់ក្រុមការងារនីមួយៗ មានវិសាលភាពគ្របដណ្តប់លើការងារដែលមានកំណត់ក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសំរេចនេះ។

ប្រការ ៤ : ប្រធានក្រុមការងារ "ឃ" ជាអ្នកសំរបសំរួលវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នឹងដើរតួជាអគ្គលេខាធិការដ្ឋាន សំរាប់បំរើយន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន។ ក្នុងពេលរង់ចាំការបង្កើតអគ្គលេខាធិការដ្ឋាននេះ ប្រធានក្រុមការងារនីមួយៗ អាចបង្កើតលេខាធិការដ្ឋាននៅតាមក្រសួង-ស្ថាប័នរបស់ខ្លួន ដោយប្រើប្រាស់មន្ត្រីរបស់ខ្លួនជាលេខាធិការ និងដោយប្រើប្រាស់ជាផ្លូវការនូវត្រារបស់ក្រសួង-ស្ថាប័នក្នុងកិច្ចទំនាក់ទំនងរាល់ការងារក្នុងក្របខ័ណ្ឌភារកិច្ច ដែលបានកំណត់ក្នុងប្រការ២ នៃសេចក្តីសំរេចនេះ។

ប្រការ ៥ : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាចំណុចកណ្តាលសំរាប់ធ្វើទំនាក់ទំនងអន្តរក្រុមការងារ និងសរុបរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

ប្រការ ៦ : សមាជិកក្រុមការងារនីមួយៗ ត្រូវចូលរួមប្រជុំអោយបានទៀងទាត់ តាមការអញ្ជើញរបស់ប្រធាន។ ប្រធានក្រុមការងារនីមួយៗ អាចអញ្ជើញថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធ មកចូលរួមការងារបានក្នុងករណីចាំបាច់។ ពេលប្រធានអវត្តមាន ក្រុមការងារអាចប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន ឬរបស់តំណាង តាមការប្រគល់សិទ្ធិរបស់ប្រធាន។

សមាសភាពទាំងអស់នៃក្រុមការងារតាមផ្នែកនីមួយៗ មានសិទ្ធិចាត់តាំងរៀងៗខ្លួននូវសមាជិកបំរុង០១រូប សំរាប់ជួយការងារ ឬជំនួស នៅពេលអវត្តមាន។

ប្រការ ៧ : រាល់បទបញ្ញត្តិដែលមានពីមុនមក និងដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

__ប្រការ ៨__ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនឹងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ៨ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

__ចំលងជូន__ :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី សហប្រធាន "គ.អ.ក"
- ខុទ្ទកាល័យសម្តេចក្រុមព្រះ សហប្រធាន "គ.អ.ក"
- ដូចប្រការ ៨
- ឯកសារ-កាលប្បវត្តិ